BRIEFING NOTES

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

០៧ កក្កដា ២០១៧

**អ្នកនាំពាក្យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស៖ អ្នកស្រី លីហ្ស ស្រូសហ្សែលល៍**

**ទីតាំង៖ ទីក្រុងហ្សឺណែវ**

**កម្មវត្ថុ៖ (១) តួគី (២) ចិន (៣) កម្ពុជា**

…………………………………………………………………………………………………………
…………………………………………………………………………………………………………
…………………………………………………………………………………………………………

**(៣) ប្រទេសកម្ពុជា**

យើងសូមសម្តែងការស្វាគមន៍អស់ពីដួងចិត្តចំពោះការដោះលែងឲ្យនៅក្រៅឃុំនូវអ្នកការពារសិទ្ធិមនុស្សចំនួនប្រាំរូប ដែលត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នចាប់ពីខែមេសា ឆ្នាំ២០១៦ ហើយយើងសូម ស្វាគមន៍ដូចគ្នាផងដែរចំពោះការទម្លាក់ចោលបទចោទប្រកាន់គ្រប់យ៉ាងតាមផ្លូវច្បាប់លើបុគ្គលិកមួយរូបនៃការិយាល័យរបស់យើងខ្ញុំផ្ទាល់ គឺ លោក ស៊ីន សាលី ដែលត្រូវបានចោទប្រកាន់នៅក្នុងករណីដូចគ្នា។ សំណុំរឿងប្រឆាំងនឹងបុគ្គលិករបស់យើងរូបនេះត្រូវបានដកចេញជាផ្លូវការនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧។

ទោះជាយ៉ាងណាក៏ដោយ ការវិវឌ្ឍដ៏វិជ្ជមានទាំងនេះ កើតមាននៅពេលមួយដែលបរិយាកាសសម្រាប់អ្នកការពារសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលនៅកម្ពុជា កំពុងតែកើតមាននូវក្តីកង្វល់ជាខ្លាំងនៅឡើយ។

ក្នុងចំណោមអ្នកដែលត្រូវបានដោះលែងឲ្យនៅក្រៅឃុំទាំងនោះមាន លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វ៉ង់ដា និងអ្នកស្រី លឹម មុន្នី គឺជាបុគ្គលិកជាន់ខ្ពស់នៃសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ចំណែកឯ លោក នី ចរិយា គឺជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អ្នកទាំងប្រាំរូបនេះ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧។

យើងខ្ញុំនៅតែមានក្ដីកង្វល់ថា ការជំនុំជម្រះក្ដីរបស់ពួកគេនឹងបន្តធ្វើ បើទោះជាមិនមានភស្តុតាង និងការលើកហេតុផលតាមផ្លូវច្បាប់គ្រប់គ្រាន់ដើម្បីផ្ដល់យុត្តិកម្មលើបទចោទប្រកាន់ទាំងនោះក្ដី។ យើងនឹងបន្តតាមឃ្លាំមើលយ៉ាងដិតដល់នូវដំណើរការក្ដីប្រឆាំងនឹងពួកគេរហូតទាល់តែករណីនេះត្រូវបានបិទបញ្ចប់ទាំងស្រុង។

## ចប់

សម្រាប់ព័ត៌មានបន្ថែមនិង***ការសាកសួរព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ*** សូមទាក់ទងមក លីហ្ស ស្រូសហ្សែលល៍ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៤៦៦ ឬតាមអ៊ីមែល៖ *ethrossell@ohchr.org)*

តើមានកង្វល់នានាអំពីពិភពលោកដែលយើងរស់នៅមែនទេ? ដូច្នេះ **សូមក្រោកឈរដើម្បីសិទ្ធិរបស់នរណាម្នាក់នៅថ្ងៃនេះ**។ # Standup4humanrights ហើយចូលទៅកាន់គេហទំព័រ http://www.standup4humanrights.org

**សូមថេកនិងចែករំលែក - ទ្វីតធឺរ: @UNHumanRights និងហ្វេសប៊ុក: unitednationshumanrights**